**សលាកបត្រព័ត៌មាន ៖** សិទ្ធិចូលរួមដោយស្មើភាពក្នុងកិច្ចការសាធារណៈ

**ទិដ្ឋភាពរួម ៖** សិទ្ធិចូលរួមដោយស្មើភាពក្នុងកិច្ចការសាធារណៈ (ឬហៅថាសិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ) គឺបង្ហាញពីដំណើរការលទ្ធិប្រជាធិបតេយ្យ។ សិទ្ធិនេះទាក់ទងយ៉ាងស្និទ្ធជាមួយនឹងសេរីភាពមូលដ្ឋាន ដូចជា សេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន។ ជាការប្រារព្ធទិវាលទ្ធិប្រជាធិបតេយ្យអន្តរជាតិ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") មានបំណងបញ្ជាក់ពីសារៈសំខាន់នៃសិទ្ធិនេះ និងលើកឡើងពីមធ្យោបាយចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ។

## សេចក្តីផ្តើម

សលាកបត្រព័ត៌មាននេះ លើកឡើងនូវទិដ្ឋភាពមួយនៃសិទ្ធិចូលរួមដោយស្មើភាពក្នុងកិច្ចការនយោបាយ និងសាធារណៈ ដូចដែលមានចែងក្នុង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ សលាកបត្រព័ត៌មាននេះ តាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("ប្រទេសកម្ពុជា")។

## តើសិទ្ធិចូលរួមដោយស្មើភាពក្នុងកិច្ចការសាធារណៈជាអ្វី?

សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈគឺជាសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី។[1] ន័យម្យ៉ាងទៀត នេះគឺជាសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការផ្នែកនយោបាយ។ សិទ្ធិនេះអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ និងការពារពួកគាត់ពីផលវិបាកអវិជ្ជមានដែលបណ្តាលមកពីការអនុវត្តសិទ្ធិនេះ។[2] មាត្រា ២១ (១) នៃ ស.ស.ស.ម និងមាត្រា ២៥ (ក) នៃ ក.អ.ស.ព.ន[3] ការពារសិទ្ធិនេះ។ សង្ខេបមក សិទ្ធិនេះចែងនូវទស្សនៈនៃលទ្ធិប្រជាធិបតេយ្យដែលជា "ប្រព័ន្ធមួយរបស់រដ្ឋាភិបាល តាមចំនួនប្រជាពលរដ្ឋទាំងមូល ឬក៏សមាជិកណាម្នាក់នៃរដ្ឋណាមួយ ជាពិសេស តាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី"។[4]

[1] ក.អ.ស.ព.ន មាត្រា ២៥ (ក) ស.ស.ស.ម មាត្រា ២១ (១)។

[2] ក.អ.ស.ព.ន មាត្រា ២៥ (ក)

[3] ស.ស.ស.ម មាត្រា ២១ (១) ក.អ.ស.ព.ន មាត្រា ២៥ (ក)

[4] វចនានុក្រមអ៊ុកស្វ៊ហ្វឺដ https://en.oxforddictionaries.com/definition/democracy បានចូលទៅនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧។

ការបង្ហាញនូវ "ការដឹកនាំកិច្ចការសាធារណៈ" ទាក់ទងទៅនឹងការអនុវត្តអំណាចនយោបាយ និងជាពិសេសការអនុវត្តអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងរដ្ឋបាល។ នេះគ្របដណ្តប់ទៅលើទិដ្ឋភាពទាំងអស់នៃរដ្ឋបាលសាធារណៈ ព្រមទាំងការបង្កើត និងការអនុវត្តគោលនយោបាយថ្នាក់អន្តរជាតិ ជាតិ តំបន់ និងមូលដ្ឋាន។[5] ការចូលរួមដោយសកម្ម និងដោយគ្មានការរារាំងរបស់ប្រជាពលរដ្ឋនៅក្នុងបរិយាកាសនយោបាយ នៅពេលពួកគាត់អនុវត្តសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈរបស់ខ្លួនដែលនេះជាការធានានូវគណនេយ្យភាព និងតម្លាភាពរបស់អ្នកតំណាងសាធារណៈ ដែលជាធាតុផ្សំសំខាន់ក្នុងដំណើរការលទ្ធិប្រជាធិតេយ្យ។[6]

សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈនេះអាចត្រូវបានអនុវត្តដោយផ្ទាល់ ឧទាហរណ៍ តាមរយៈការចូលរួមជាសមាជិកនៃស្ថាប័ននីតិប្បញ្ញត្តិ ការទទួលតំណែងខាងនីតិប្រតិបត្តិ នៅពេលពួកគាត់ចូលរួមក្នុងការធ្វើប្រជាមតិ ឬតាមរយៈការចូលរួមក្នុងការប្រមូលផ្តុំនៅមូលដ្ឋាន ឬតាមស្ថាប័ននានាដែលបង្កើតឡើងដើម្បីតំណាងពលរដ្ឋក្នុងការប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាល។[7] លើសពីនេះ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ ជារឿយៗត្រូវបានអនុវត្តដោយប្រយោលតាមរយៈអ្នកតំណាង។ ក្នុងករណីនេះ អ្នកតំណាងទាំងនោះគួរតែត្រូវបានប្រជាពលរដ្ឋជ្រើសរើសដោយសេរី អាស្រ័យទៅតាមដំណើរការបោះឆ្នោតដែលបង្កើតឡើងដោយច្បាប់ និងការគោរពសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិ។[8] អ្នកតំណាងទាំងនោះអាចអនុវត្តត្រឹមតែអំណាចដែលខ្លួនមានប៉ុណ្ណោះ ដោយអនុលោមតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងមានទំនួលខុសត្រូវតាមរយៈដំណើរការបោះឆ្នោត។[9]

សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈអនុវត្តយ៉ាងស្មើភាពចំពោះប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ សិទ្ធិនេះត្រូវទទួលបានការគោរព និងការទទួលស្គាល់ដោយពុំមានការរើសអើងដោយផ្អែកលើ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។[10] លើសពីនេះ សិទ្ធិនេះមិនត្រូវរង "ការរឹតត្បិតដោយពុំសមហេតុផល" នោះឡើយ។[11] ខណៈដែលសិទ្ធិនេះអាចត្រូវបានរឹតត្បិតលើពលរដ្ឋជាក់ស្តែង ដូចដែលមានចែងក្នុងច្បាប់ជាតិរបស់កម្ពុជាក្តី[12] តែការរឹតត្បិតនេះគួរតែត្រូវបកស្រាយឱ្យបានទូលំទូលាយ ព្រោះថាក្នុងពេលដូចគ្នានេះ ការអនុវត្តសិទ្ធិនេះមិនត្រូវរើសអើងដោយផ្អែកលើកំណើត ឬស្ថានភាពដទៃទៀតឡើយ។

## សិទ្ធិចូលរួមដោយស្មើភាពក្នុងការងារសាធារណៈត្រូវបានធានាក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ

[5] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការអត្ថាធិប្បាយទូទៅ លេខ២៥ មាត្រា២៥ សិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានសេវាសាធារណៈដោយស្មើភាព CCPR/C/21/1/7, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៦ កថាខ័ណ្ឌ៥ ("ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប")។

[6] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ២៥ កថាខ័ណ្ឌ២, ៧។

[7] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ៦។

[8] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ៦។

[9] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ៧ ។

[10] ក.អ.ស.ព.ន មាត្រា ២ ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ៣។

[11] ក.អ.ស.ព.ន មាត្រា ២៥។

[12] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ៣។

ក្រោមរដ្ឋធម្មនុញ្ញកម្ពុជា ប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ អនុលោមតាមមាត្រា ៣៥។ ម្យ៉ាងទៀត សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ "ត្រូវបានទទួលការពិនិត្យដោយពេញលេញ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ"។[13] ប្រជាពលរដ្ឋគ្រប់រូបក៏មានសិទ្ធិខាងការប្រជុំដោយសន្តិវិធី និងទទួលបានការការពារពីការវាយដំលើរាងកាយ ដូចដែលមានគូសបញ្ជាក់ក្នុងមាត្រា៣៧ និងមាត្រា៣៨ ដោយឡែកពីគ្នា។ រដ្ឋធម្មនុញ្ញក៏ទទួលស្គាល់ផងដែរថាពលរដ្ឋទាំងអស់មានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងធានាសិទ្ធិផ្នែកសារព័ត៌មាន ការបោះពុម្ពផ្សាយ និងការប្រមូលផ្តុំ។[14]

ម្យ៉ាងទៀត មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា ប្រទេសកម្ពុជាទទួលស្គាល់សិទ្ធិមនុស្សអន្តរជាតិដូចមានចែងក្នុង ស.ស.ស.ម ព្រមទាំងសន្ធិសញ្ញា និងអនុសញ្ញាស្តីពីសិទ្ធិមនុស្សដទៃទៀត ក្នុងនោះរួមទាំង ក.អ.ស.ព.ន ផង។[15] ស.ស.ស.ម ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិចូលរួមក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលត្រូវបានជ្រើសរើសដោយសេរី"។[16] ក.អ.ស.ព.ន ចែងថាប្រជាពលរដ្ឋមានសិទ្ធិរួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី។[17]

លិខិតូបករណ៍អន្តរជាតិដទៃទៀតដែលកម្ពុជាបានផ្តល់សច្ចាប័នក៏ការពារសិទ្ធិនេះផងដែរ ក្នុងចំណោមលិខិតូបករណ៍ទាំងនោះ មានដូចជា អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងសេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិជាដើម។

## ទំនាក់ទំនងជាមួយសិទ្ធិមនុស្សដទៃទៀត

សិទ្ធិចូលរួមក្នុងកិច្ចការនយោបាយ និងសាធារណៈគឺមានទំនាក់ទំនងយ៉ាងស្និទ្ធជាមួយសិទ្ធិធ្វើសេចក្តីសម្រេចលើជោគវាសនាដោយផ្ទាល់ខ្លួន សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ព្រមទាំងសិទ្ធិសេរីភាពខាងសមាគម និងការប្រមូលផ្តុំ។[18]

សិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើជោគវាសនាដោយផ្ទាល់ខ្លួន មានន័យថា ប្រជាពលរដ្ឋមានសិទ្ធិ "កំណត់នូវស្ថានភាពនយោបាយរបស់ខ្លួនដោយសេរី និងមានសិទ្ធិក្នុងការជ្រើសរើសទម្រង់នៃរដ្ឋធម្មនុញ្ញ ឬរដ្ឋាភិបាលរបស់ខ្លួន"។[19] ជាសង្ខេប ប្រជាពលរដ្ឋទោះជាជនជាតិអ្វីក៏ដោយ នឹងមានសិទ្ធិឈរឈ្មោះបោះឆ្នោត និងចូលរួមក្នុងកិច្ចការសាធារណៈនានាដែលធ្វើឱ្យប្រសើរដល់រដ្ឋាភិបាល និងច្បាប់របស់ពួកគេ។

---

[13] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៥។

[14] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៤១ ។

[15] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ ។

[16] ស.ស.ស.ម មាត្រា២១ (១)។

[17] ក.អ.ស.ព.ន មាត្រា២៥ (ក)។

[18] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ២៥ កថាខ័ណ្ឌ ៨។

[19] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ២៥ កថាខ័ណ្ឌ ២។

សេរីភាពខាងការបញ្ចេញមតិ សមាគម និងប្រមូលផ្តុំមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួតជាមួយសិទ្ធិចូលរួមដោយស្មើភាពក្នុងកិច្ចការនយោបាយ និងសាធារណៈ។[20] សារគមនាគមន៍នៃព័ត៌មាន និងគំនិតដោយសេរីអំពីបញ្ហាសាធារណៈ និងនយោបាយ រវាងប្រជាពលរដ្ឋ បេក្ខជន និងតំណាងដែលខ្លួនជ្រើសតាំងមានសារៈសំខាន់ណាស់។[21] នេះតម្រូវឱ្យមានសារព័ត៌មានដោយសេរី និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដទៃទៀតដែលអាចលើកឡើងអំពីបញ្ហាសាធារណៈដោយពុំមានការត្រួតពិនិត្យ ឬការរឹតត្បិត និងអាចលើកឡើងនូវគំនិតយោបល់ជាសាធារណៈ។[22] ដូច្នេះដើម្បីអាចចូលរួមឱ្យបានពេញលេញក្នុងកិច្ចការសាធារណៈ ប្រជាពលរដ្ឋត្រូវមានសិទ្ធិទទួលបានព័ត៌មាន។[23]

## តើសិទ្ធិនេះមានន័យដូចម្តេចតាមការអនុវត្តជាក់ស្តែង?

របៀបក្នុងការបែងចែកអំណាចច្បាស់លាស់ និងវិធីដែលប្រជាពលរដ្ឋម្នាក់ៗអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមដឹកនាំកិច្ចការសាធារណៈ ត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ដទៃទៀត។[24]

យ៉ាងណាក្តី សកម្មភាពមូលដ្ឋានជាក់លាក់មួយចំនួនត្រូវបានការពារក្រោមសិទ្ធិនេះ ដូចជា ៖

- សិទ្ធិក្នុងការរៀបចំបាតុកម្មដោយសន្តិវិធី
- សិទ្ធិក្នុងការមានបេក្ខជនសម្រាប់ជ្រើសរើសដោយសេរី។ ជាពិសេស បុគ្គលដែលមានសិទ្ធិឈរឈ្មោះបោះឆ្នោតមិនគួរត្រូវបានផាត់ចេញដោយលក្ខខណ្ឌតម្រូវដែលពុំសមហេតុផល ឬ មានលក្ខណៈរើសអើង ដូចជា ការអប់រំ សិទ្ធិទទួលបានលំនៅដ្ឋាន ឬដោយសមរម្យ ឬ ដោយហេតុផលនៃទំនាក់ទំនងនយោបាយ
- សិទ្ធិជ្រើសរើសបេក្ខជនដោយស្មើភាព និងសិទ្ធិឈរឈ្មោះបោះឆ្នោត
- លទ្ធភាពប្រើប្រាស់ឥទ្ធិពលតាមរយៈកិច្ចពិភាក្សា និងកិច្ចសន្ទនាសាធារណៈ ជាមួយតំណាងរបស់ខ្លួន ឬតាមរយៈសមត្ថភាពក្នុងការរៀបចំដោយខ្លួនឯង ម្យ៉ាងទៀត ដើម្បីចូលរួមក្នុងកិច្ចសន្ទនា ចូលរួមក្នុងកិច្ចពិភាក្សាជាមួយអ្នកតំណាងរបស់ខ្លួន និងប្រមូលផ្តុំដោយសន្តិវិធីដើម្បីពិភាក្សាអំពីបញ្ហានយោបាយ
- សេរីភាពក្នុងការ រិះគន់ និងជំទាស់ ចេញផ្សាយឯកសារផ្នែកនយោបាយ ធ្វើយុទ្ធនាការសម្រាប់ការបោះឆ្នោត និងផ្សព្វផ្សាយនូវទស្សនៈនយោបាយ
- សេរីភាពក្នុងការទទួលបានព័ត៌មាន និងការបោះពុម្ពផ្សាយទាក់ទងទៅនឹងកិច្ចការនយោបាយ និងសាធារណៈ និងមានយោបល់ទៅលើបញ្ហាសាធារណៈដោយពុំមានការត្រួតពិនិត្យ ឬការទប់ស្កាត់ និងលើកឡើងនូវគំនិតជាសាធារណៈ។[25]

---

[20] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខណ្ឌ ១២។

[21] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ៣៤ មាត្រា ១៩ ៖ សេរីភាពខាងគំនិត និងការបញ្ចេញមតិ CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ១៣ ។

[22] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ៣៤ កថាខណ្ឌ ១៣។

[23] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ៣៤ កថាខណ្ឌ ១៨។

[24] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ២៥ កថាខណ្ឌ ៥។

ម្យ៉ាងទៀត សិទ្ធិនេះក៏រាប់បញ្ចូលនូវលទ្ធភាពក្នុងការចែកចាយព័ត៌មានស្ដីពីការបោះឆ្នោត ដូចជាប័ណ្ណព័ត៌មាន និងខិត្តបណ្ណ[26] ឬដើម្បីផ្ដល់លទ្ធផលថ្មីៗនៃការបោះឆ្នោតតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។[27]

សិទ្ធិក្នុងការចូលរួមកិច្ចការសាធារណៈរបស់ប្រជាពលរដ្ឋត្រូវបានការពារក្រោមក្របខ័ណ្ឌច្បាប់កម្ពុជា។ រដ្ឋាភិបាលបានផ្ដល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិជាច្រើនដែលជាការធានាដល់កិច្ចការពាររបស់ខ្លួន ហើយសិទ្ធិនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដូចបានលើកឡើងខាងលើ។ ទោះបីជាក្របខ័ណ្ឌច្បាប់ដ៏រឹងមាំនេះទទួលបានការស្វាគមន៍ក្ដី តាមជាក់ស្ដែងនៅមានចំណុចជាច្រើនដែលពុំទាន់បានអនុវត្ត ដើម្បីការពារសិទ្ធិនេះឱ្យកាន់តែមានប្រសិទ្ធភាព។ គណបក្សនយោបាយ អ្នកវិភាគ សហជីព អ្នកការពារសិទ្ធិមនុស្ស ព្រមទាំងសមាជិកនៃសង្គមស៊ីវិលពុំអាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួនដោយពុំមានការរារាំងឡើយ។ ផ្ទុយទៅវិញ បរិយាកាសភ័យខ្លាច និងបុគ្គលមួយចំនួនអាចប្រឈមនឹងការបង្ក្រាបនៅពេលពួកគាត់ព្យាយាមចូលរួមក្នុងជីវភាពសាធារណៈ។ ដើម្បីឱ្យរដ្ឋាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ត្រូវតែអនុញ្ញាតឱ្យពលរដ្ឋរបស់ខ្លួនចូលរួមដោយសេរីក្នុងការដឹកនាំកិច្ចការសាធារណៈ ដោយពុំមានការរើសអើង ហើយជាពិសេសនោះ ពុំមានការរឹតត្បិតដោយពុំសមហេតុផល។ សេរីភាពខាងការបញ្ចេញមតិរបស់ពលរដ្ឋ រួមមាន សិទ្ធិទទួលបានព័ត៌មានត្រូវតែបានគេគោរពដើម្បីធានាថាលទ្ធិប្រជាធិបតេយ្យមានពិតប្រាកដនៅកម្ពុជា។

## សេចក្ដីសន្និដ្ឋាន

ជាទូទៅ តាមជាក់ស្ដែងសិទ្ធិនេះលើកឡើងពីកាលានុវត្តភាពសម្រាប់បុគ្គលនីមួយៗ ដើម្បីអាចចូលរួមក្នុងជីវភាពនយោបាយរបស់ប្រទេសរបស់ខ្លួនតាមរយៈការសម្ដែងមតិយោបល់ដោយសេរី ការបោះឆ្នោត ការចូលរួមក្នុងកិច្ចពិភាក្សា និងការរៀបចំការបោះឆ្នោត ដោយពុំមានការភ័យខ្លាចពីផលវិបាកអវិជ្ជមាន។ ទាំងនេះ គឺជាសិទ្ធិសម្រាប់ប្រជាពលរដ្ឋក្នុងការកំណត់ដោយសេរីនូវស្ថានភាពនយោបាយរបស់ខ្លួន និងជ្រើសរើសនូវទម្រង់នៃរដ្ឋធម្មនុញ្ញ ឬរដ្ឋាភិបាលរបស់ខ្លួន។[28]

សិទ្ធិចូលរួមដោយស្មើភាពក្នុងជីវភាពនយោបាយ និងកិច្ចការសាធារណៈរួមជាមួយសិទ្ធិមនុស្សសំខាន់ៗមួយចំនួនទៀតដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ សិទ្ធិនេះគឺជាបញ្ញត្តិនៃរដ្ឋធម្មនុញ្ញដ៏សំខាន់ដែលការពារលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើសេចក្ដីសម្រេច និងចូលរួមក្នុងវិស័យនយោបាយរៀងៗខ្លួនរបស់ពួកគាត់។ សិទ្ធិនេះអនុញ្ញាតឱ្យមានសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្ដុំ និងសមាគម ព្រមទាំងបង្កើតនូវលំហសុវត្ថិភាពសម្រាប់ការចូលរួមផ្នែកនយោបាយនៅតាមកម្រិតផ្សេងៗ។ សិទ្ធិមនុស្សដែលមានសារៈសំខាន់នេះ គួរត្រូវតែបានលើកតម្កើងជានិច្ចដើម្បីធានាថាដំណើរការលទ្ធិប្រជាធិបតេយ្យមានលក្ខណៈសេរី និងយុត្តិធម៌។

[25] ការអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ២៥ កថាខ័ណ្ឌ ១០ ១២ ១៥ ១៩ ២៥។

[26] គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប កូនីនកូ & មីលីនកេវិច និង បេឡារ៉ុស សារគមនាគមន៍ លេខ 553/2007, CCPR/C/95/D/1553/2007 ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ កថាខ័ណ្ឌ ៨.៤។

[27] គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប ចុង-ចែល និងសាធារណៈរដ្ឋកូរ៉េ សារគមនាគមន៍ លេខ 968/2001, CCPR/C/84/D/968 /2001 ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ កថាខ័ណ្ឌ ៨.២។

[28] ការអត្ថាធិប្បាយទូទៅនៃគណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ២៥ កថាខ័ណ្ឌ ២។